ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៨៥/១៤ - វ៉ាយ ធី ស៊ី ខបប៉ូរេសិន

កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង វូចហ៊ុន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន វ៉ាយ ធី ស៊ី ខបប៉ូរេសិន**

អាសយដ្ឋាន ៖ ភូមិវល្លិស ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

ទូរស័ព្ទ ៖ ០៨៩ ៩៦៦ ២២៧　　　　ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក លី ប៊្យុងប៊ុង | នាយកក្រុមហ៊ុន |
| ២- លោកស្រី គង់ សុគន្ធា | ប្រធានរដ្ឋបាល |
| ៣- លោកស្រី ទូ ផាន់ដា | ជំនួយការរដ្ឋបាល |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **សហព័ន្ធសហជីពសម្លេងកម្មករកម្ពុជា**

អាសយដ្ឋាន ៖ ផ្ទះលេខ ៣១៧ ផ្លូវលំ សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩២ ៧៧៦ ៨៦២　　　　ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖ គ្មាន

## បញ្ហាក្តូវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

២. សុំក្រុមហ៊ុនតម្លើងលុយព្រីម (រង្វាន់ការងារទៀងទាត់) ចំនួន ២០ ដុល្លារ ។

៣. សុំក្រុមហ៊ុនផ្តល់លុយធ្វើដំណើរចំនួន ២០ ដុល្លារ ។

៤. សុំក្រុមហ៊ុនផ្តល់លុយបាយថ្ងៃត្រង់ចំនួន ៥០០០ រៀល ក្នុងមួយថ្ងៃ ។

៦. សុំឱ្យក្រុមហ៊ុនផ្តល់លុយសហការចំនួន ២០ ដុល្លារ ក្នុងមួយខែ ។

៨. សុំឱ្យក្រុមហ៊ុនផ្តល់លុយទឹកដោះគោចំនួន ១៥ ដុល្លារ ក្នុងមួយខែ ។

៩. សុំក្រុមហ៊ុនផ្តល់លុយបាយចំនួន ២០០០ រៀល ក្នុងមួយម៉ោង នៅពេលកម្មករធ្វើការថែមម៉ោង ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៤៥៥/១៤ របក/កស្គ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល ) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ បានទទួលលិខិតជូនដំណឹងធ្វើកូដកម្មនៅក្រុមហ៊ុន វ៉ាយ ធី ស៊ី ដែលដឹកនាំដោយសហព័ន្ធសហជីព សម្លេងកម្មករកម្ពុជា ដើម្បីទាមទារលក្ខខណ្ឌការងារចំនួន ១១ ចំណុច ។ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងធ្វើកូដកម្មរបស់កម្មករនិយោជិតនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ បានចាត់មន្ត្រីជំនាញឱ្យធ្វើការអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មាន នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤ និងផ្សះផ្សាវិវាទការងាររួមចំនួន ១១ ចំណុចនេះ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០៥ ចំណុច និងមិនសះជានឹងគ្នាចំនួន ០៦ ចំណុច ។ ចំណុចមិន

សះជាចំនួន ០៦ ចំណុច ដែលនៅសល់នេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ តាមរយៈរបាយការណ៍ស្តីពីការផ្សះផ្សាវិវាទការងាររួមនៃក្រុមហ៊ុន វ៉ាយធីស៊ី ខបភើរេសិន លេខ ៤៥៥/១៤ របក/ក.ស្ក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៦ ចំណុចនេះ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៤ វេលាម៉ោង ០២៖០០ នាទីរសៀល។ ដោយឡែកភាគីនិយោជកបានស្នើសុំលើកពេលសវនាការអាជ្ញាកណ្តាល តាមរយៈលិខិតលេខ YJCAM/APR/08-14 ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤ របស់និយោជក ដោយសារមូលហេតុថា លោកនាយកក្រុមហ៊ុន មានការមមាញឹកក្នុងការងារក្រុមហ៊ុន។ ដូចនេះ សវនាការអាជ្ញាកណ្តាលត្រូវបានពន្យារពេលទៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ វេលាម៉ោង ០២៖០០ នាទីរសៀលវិញ។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៦ ចំណុចនេះ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ វេលាម៉ោង ០២៖០០ នាទី រសៀល។

នៅថ្ងៃសវនាការ នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ភាគីនិយោជកបានមកចូលរួមសវនាការតាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏ប៉ុន្តែ ភាគីកម្មករនិយោជិតមិនបានមកចូលរួមសវនាការទេ។ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ដដែល វេលាម៉ោង ០២៖១០ នាទីរសៀល លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការទំនាក់ទំនងតាមទូរស័ព្ទទៅកាន់ លោក ផន ម៉ៃ ដែលជាប្រធានសហព័ន្ធសហជីពសម្លេងកម្មករកម្ពុជា និងជាតំណាងភាគីកម្មករនិយោជិត។ តាមរយៈទំនាក់ទំនងតាមទូរស័ព្ទនេះ លោក ផន ម៉ៃ បានប្រាប់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា លោកមិនអាចចូលរួមសវនាការទេ ព្រោះលោកកំពុងនៅខេត្តស្វាយរៀង ហើយឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើសវនាការសម្រេចសេចក្តី ដោយអវត្តមានភាគីកម្មករនិយោជិត។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា ដូចខាងក្រោម ៖

**តស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖គ្មាន**

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- កំណត់ហេតុស្តីពីការប្រជុំរវាងតំណាងនាយកក្រុមហ៊ុន ប្រធានផ្នែក តំណាងកម្មករនិយោជិត និងថ្នាក់ដឹកនាំសហជីពប្រចាំក្រុមហ៊ុន ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៣។

២- អនុសញ្ញារួមនៃការងាររវាងសហជីពកម្មករកម្ពុជា រោងចក្រ វ៉ាយធីស៊ី ខបប៉ូរេសិន ជាសមាជិកសហព័ន្ធសហជីពកម្មករកម្ពុជា និងក្រុមហ៊ុន វ៉ាយធីស៊ី ខបប៉ូរេសិន អាណត្តិទី១ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ ដល់ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤។

៣- វិញ្ញាបនប័ត្រលេខ ៦៩៥៦ ពណ.ចបព ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ បញ្ជាក់ការចុះឈ្មោះក្នុងបញ្ជី

ពាណិជ្ជកម្មក្រុមហ៊ុន វ៉ាយ ធី ស៊ី ខបប៉ូរេសិន ។

៤- លិខិតរបស់ក្រុមហ៊ុន វ៉ាយ ធី ស៊ី ខបប៉ូរេសិន គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីសំណើសុំចុះទិដ្ឋាការលើបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ។

៥- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន វ៉ាយ ធី ស៊ី ខបប៉ូរេសិន បានចុះទិដ្ឋាការលេខ ៨៣១ កប/កស្ត ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១១។

៦- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន វ៉ាយ ធី ស៊ី ខបប៉ូរេសិន ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤។

៧- លក្ខន្តិកៈក្រុមហ៊ុន វ៉ាយ ធី ស៊ី ខបប៉ូរេសិន តំកល់ទុកលេខ ១៦៨៨/០៦ ពណ.ចបព ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន វ៉ាយ ធី ស៊ី ខបប៉ូរេសិន លេខ ៤៥៥/១៤ របក/កស្ត ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន វ៉ាយ ធី ស៊ី ខបប៉ូរេសិន ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៤៣៣ កប/អក/វក/លកអ. ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤។

២- លិខិតអញ្ជើញភាគីនិយោជិតចូលរួមសវនាការ លេខ ៣៣២ កប/អក/វក/លកអ. ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទ ដែលចែងនៅក្នុងរបាយការណ៍មិនសះជា របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារភាគីដើមបណ្តឹងមិនបានមកចូលរួមសវនាការទេ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ វេលាម៉ោង ០២៖០០ នាទីរសៀល។ ភាគីនិយោជកបានមកចូលរួមសវនាការ នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុម

ប្រឹក្សាអាជ្ញាកណ្តាល ក៏ប៉ុន្តែ ភាគីកម្មករនិយោជិតមិនបានមកចូលរួមសវនាការទេ។ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ដដែល វេលាម៉ោង ០២៖១០ នាទីរសៀល លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការទំនាក់ទំនងតាមទូរស័ព្ទទៅកាន់ លោក ផន ម៉ៃ ដែលជាប្រធានសហព័ន្ធសហជីពសម្លេងកម្មករកម្ពុជា និងជាតំណាងភាគីកម្មករនិយោជិត។ តាមរយៈទំនាក់ទំនងតាមទូរស័ព្ទនេះ លោក ផន ម៉ៃ បានប្រាប់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា លោកមិនអាចចូលរួមសវនាការទេ ព្រោះលោកកំពុងនៅខេត្តស្វាយរៀង ហើយឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើសវនាការសម្រេចសេចក្តី ដោយអវត្តមានភាគីកម្មករនិយោជិត។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាថា តើនឹងត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ ក្នុងករណីអវត្តមានដើមបណ្តឹង?

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលប្រការ ២១ ចែងថា *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួនទៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់ "* ។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាលមុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន"* ។

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសតី, លេខ ២៧/០៧-អ៊ីម និង វ៉េ ៣, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១១/១១-ជូន តិចថាយល៍, លេខ ១៣១/១២-ម៉ាស្ទ័រ & ហ្វ្រែង និងលេខ ១២៩/១៣-ក្លូប័ល អាប៉ារ៉ែល ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយ ប្រការ២១ ខាងលើនេះថា មានលក្ខខណ្ឌបីដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាល *លក្ខខណ្ឌទី១ ៖ ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ, លក្ខខណ្ឌទី២៖ ភាគីមិនបានបង្ហាញខ្លួនទៅចំពោះ មុខក្រុមអាជ្ញាកណ្តាល និងលក្ខខណ្ឌទី៣ ៖ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន"* ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗខាងលើដែរ។ ហេតុនេះ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើលក្ខខណ្ឌទាំងបីនេះត្រូវបានបំពេញដែរ ឬទេ?

**លក្ខខណ្ឌទី ១ ៖ ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ**

មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទំនាក់ទំនងទៅកាន់ភាគីកម្មករនិយោជិត ដោយជូនដំណឹងពីសវនាការ នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ វេលាម៉ោង ០២៖០០ នាទី រសៀល តាមរយៈលិខិតអញ្ជើញ

លេខ ៣៣២ កប/អក/វក/លកអ. ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ ដោយមានលោក ផន ម៉ៃ ជាប្រធានសហព័ន្ធសហជីពសម្លេងកម្មករកម្ពុជា ជាអ្នកបានចុះហត្ថលេខាទទួល នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ២ ៖ *ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល***

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា *"ពាក្យបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល"* នៅក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មានន័យថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតចប់សព្វគ្រប់។ ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាលដូចជា ៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

ក្នុងករណីនេះ លោក ផន ម៉ៃ ដែលជាប្រធានសហព័ន្ធសហជីពសម្លេងកម្មករកម្ពុជា និងជាតំណាងភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ មិនបានអញ្ជើញមកចូលរួមសវនាការអាជ្ញាកណ្តាលទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនបានបង្ហាញខ្លួននៅក្នុងសវនាការទេ។ ហេតុនេះ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ។

**លក្ខខណ្ឌទី៣ ៖ *ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន***

នៅក្នុងករណីនេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកចូលរួមសវនាការ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ វេលាម៉ោង ០២៖០០ នាទីរសៀល។ ផ្ទុយទៅវិញ ភាគីកម្មករនិយោជិតមិនបានប្រាប់មូលហេតុ ឬព័តិមានដែលខ្លួនមិនអាចចូលរួមសវនាការបាននោះទេ រហូតដល់ថ្ងៃសវនាការ នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ វេលាម៉ោង ០២៖១០ នាទីរសៀល លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការទំនាក់ទំនងតាមទូរស័ព្ទទៅកាន់ លោក ផន ម៉ៃ ដែលជាប្រធានសហព័ន្ធ សហជីពសម្លេងកម្មករកម្ពុជា និងជាតំណាងភាគីកម្មករនិយោជិត ទើបគាត់ប្រាប់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា គាត់មិនអាចចូលរួមសវនាការទេ ព្រោះគាត់កំពុងនៅខេត្តស្វាយរៀង ហើយឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើសវនាការសម្រេចសេចក្តី ដោយអវត្តមានភាគីកម្មករនិយោជិត។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននៅក្នុងសវនាការនោះទេ។ ហេតុនេះ លក្ខខណ្ឌទី៣ ក៏ ត្រូវបានបំពេញដែរ។

សរុបសេចក្តីមក លក្ខខណ្ឌទាំងបីដែលមានចែងក្នុងប្រការ ២១ ខាងលើ ត្រូវបានបំពេញ។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិត គឺជាភាគីដើមបណ្តឹង។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កាតព្វកិច្ចរបស់ភាគីដើមបណ្តឹង និងភាគីចុងបណ្តឹងនៃសំណុំរឿងវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺត្រូវ

មកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបកស្រាយបង្ហាញ ដោយផ្ទាល់មាត់ នូវការអះអាងរបស់ខ្លួន ក៏ដូចជាផ្តល់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗ ដែលពាក់ព័ន្ធនឹងចំណុចវិវាទ សម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងសម្រេចសេចក្តី។

ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធ នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងទាមទាររបស់ខ្លួន។ ចំណែកឯភាគីចុងបណ្តឹងមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធ នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះបន្ទុករបស់ខ្លួនពីការទាមទារ ឬការចោទប្រកាន់ពីសំណាក់ដើមបណ្តឹង ដែលកាតព្វកិច្ចនេះ ជាទូទៅ នឹងត្រូវកើតឡើងក្រោយពេលដែលដើមបណ្តឹងបានបំពេញកាតព្វកិច្ចរបស់ខ្លួនជាមុនសិន។

ក្នុងសំណុំរឿងនេះ ភាគីដើមបណ្តឹងមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបំពេញនូវកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។ លើសពីនេះ ភាគីដើមបណ្តឹងក៏មិនមានមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះដែរ។ ហេតុនេះ ផ្អែកតាមវិធាន និងប្រកាស ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា ភាគីដើមបណ្តឹងបានបោះបង់ចោលពាក្យបណ្តឹងរបស់ខ្លួន។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ **៨៥/១៤ - វ៉ាយ ធី ស៊ី ខបប៉ូរេីរេសិន** នេះ។

យោងតាមហេតុផលខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅ ៖

## សម្រេច និង បង្គាប់

បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ៨៥/១៤ - **វ៉ាយ ធី ស៊ី ខបប៉ូរេីរេសិន**។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក**

ឈ្មោះ ៖ **សេង ទួចហ៊ុន**

ហត្ថលេខា ៖ -----------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **អន ណន**

ហត្ថលេខា ៖ -----------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល**

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ -----------------------------

THE ARBITRATION COUNCIL